## ខេត្តកំពង់ចាម

## សក្តានុពលវិនិយោគ

មិថុនា ឆ្នាំ ២០០៨




# ខេត្តកំពង់ចាម

## បរិយាកាសអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ









USAID
ជំនួយពីពលរដ្ឋអាមេរិក

**បញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកនោះទេ។




# របាយការណ៍វិនិយោគខេត្តកំពង់ចាម


**មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត** ........ ២

**ចំណុចខ្លាំងរបស់ប្រទេស** ........ ៣

បរិយាកាសអាជីវកម្មបើកចំហ
កំលាំងពលកម្មដែលមានតម្លៃទាប
ទីតាំងយុទ្ធសាស្ត្រក្នុងតំបន់

**តើហេតុអ្វីជ្រើសរើសយកខេត្តកំពង់ចាម?** ........ ៤

១. បរិយាកាសអាជីវកម្មល្អបំផុតនៅក្នុងប្រទេសកម្ពុជា
២. ទីតាំង -មជ្ឈមណ្ឌលដឹកជញ្ជូននៅចំកណ្តាលប្រទេសកម្ពុជា
៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខគេ ដើម្បីជំរុញលើកទឹកចិត្តពាណិជ្ជកម្មដែលអាចរកប្រាក់ចំណេញបាន
៤. កំលាំងពលកម្ម - ច្រើន វ័យក្មេង មានការអប់រំ តម្លៃឈ្នួលពលកម្មទាប
៥. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏រឹងមាំ
៦. អចលនទ្រព្យមានតម្លៃខ្ពស់លើសលប់
៧. ការផ្គត់ផ្គង់អគ្គិសនី

**ឧស្សាហកម្មសំខាន់ៗរបស់ខេត្តកំពង់ចាម** ........ ៦

**ឱកាសអាជីវកម្ម** ........ ៧

**ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ** ........ ៧

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** ........ ៨

**ស្ថិតិ** ........ ៩


របាយការណ៍វិនិយោគនេះផលិតដោយ EMC សំរាប់គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។









## មតិស្វាគមន៍ពីឯកឧត្តមអភិបាលខេត្ត

ខេត្តកំពង់ចាមត្រូវបានគេស្គាល់ជាយូរណាស់មកហើយថាជាមជ្ឈមណ្ឌលកសិកម្មរបស់ប្រទេសកម្ពុជា។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ កសិពាណិជ្ជកម្មបានលើកកំពស់សេដ្ឋកិច្ចតំបន់ព្រមទាំងជំរុញឱ្យយើងឈានទៅរកភាពថ្កុំថ្កើនទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ កសិពាណិជ្ជកម្ម បានផ្ដល់នូវមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបន្ថែមទៀត ព្រមទាំងផ្ដល់ឱកាសវិនិយោគទុនផ្សេងទៀត។

បច្ចុប្បន្ននេះ សេដ្ឋកិច្ចតំបន់ប្រចាំខេត្តកំពង់ចាម មានដំណាំកសិផលផ្សេងជាច្រើនក្រៅពីដំណាំស្រូវ និងដំណាំដំឡូង។ ដោយមានប្រជាពលរដ្ឋវ័យក្មេង ប្រកបដោយសេចក្ដីឧស្សាហ៍ព្យាយាម មានចំណេះដឹង និងកំលាំងមាំមួនប្រមាណជិតពីរលាននាក់ យើងសូមធ្វើជាតំណាងឱ្យអនាគតនៃសេដ្ឋកិច្ចដែលមានកំណើនយ៉ាងឆាប់រហ័សព្រមទាំងតំណាងឱ្យសង្គមដែលកំពុងមានការអភិវឌ្ឍន៍។ យើងស្ថិតនៅចំនុចកណ្ដាល រវាងទីប្រជុំជនសំខាន់ៗ ហើយខេត្តយើងក៏ជាកន្លែងដែលមានការរីកដុះដាលខាងការងារច្នៃប្រឌិត ព្រមទាំងមុខរបរអាជីវកម្មដែលកំពុងតែមានការរីកចំរើនផងដែរ។

ដើម្បីបន្ដលើកកំពស់មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសយើង និងបន្តពង្រឹងកិត្តិស័ព្ទរបស់យើងជាតំបន់អនុគ្រោះដល់ផ្នែកវិនិយោគទុនប្រចាំប្រទេសកម្ពុជានោះ អាជ្ញាធរខេត្តកំពង់ចាមបានបំពេញការងាររបស់ខ្លួនយ៉ាងសកម្ម ដើម្បីពង្រឹងបរិយាកាសអាជីវកម្ម។ កិច្ចប្រឹងប្រែងរបស់យើងបានធ្វើឱ្យខេត្តកំពង់ចាមត្រូវបានចាត់ទុកជាខេត្តដែលជាប់លំដាប់ថ្នាក់លេខ ១ ផ្នែកបរិយាកាសអាជីវកម្មនៅក្នុងប្រទេសកម្ពុជា[1]។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនបញ្ឈប់ត្រឹមនេះដែរ។ យើងនៅតែបន្តកែលំអខេត្តរបស់យើងឱ្យកាន់តែមានការទាក់ទាញវិនិយោគទុនបន្ថែមទៀត ព្រមទាំងថែរក្សាសហគ្រាសពាណិជ្ជកម្មដែលមានស្រាប់ឱ្យបានគង់វង្សទៀតផង។ យើងរីករាយចំពោះសក្តានុពលភាពក្នុងការពង្រឹងនិងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់យើង ព្រមទាំងបើកចំហទទួលស្វាគមន៍វិនិយោគិនទាំងក្នុង និងក្រៅប្រទេសថែមទៀត។ យើងនឹងព្យាយាមឱ្យអស់ពីលទ្ធភាពដើម្បីបង្កលក្ខណៈងាយស្រួល និងធ្វើឱ្យវិនិយោគិនចំណាយធនធានតិចក្នុងការបង្កើត និងការប្រកបមុខជំនួញរបស់ខ្លួន ហើយយើងនឹងប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដើម្បីផ្ដល់បរិយាកាសអាជីវកម្មប្រកបដោយស្ថេរភាព និងអាចទុកចិត្តបាន។

ខ្ញុំសូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិដែលបានជួយឧបត្ថម្ភក្នុងការរៀបចំបង្កើតរបាយការណ៍ វិនិយោគនិងបានបន្តគាំទ្រលើការផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តរបស់យើងខ្ញុំ។

ខ្ញុំទន្ទឹងរង់ចាំធ្វើការជាមួយវិនិយោគិនទាំងអស់ដើម្បីជួយការធ្វើឱ្យអាជីវកម្មរបស់ពួកគេព្រមទាំងខេត្តដែលមានសក្តានុពលរបស់យើងនេះ កាន់តែមានភាពរីកចំរើនឡើងថែមទៀត។

សូមទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។



**ឯកឧត្តម ហ៊ុន ណេង**
អភិបាលខេត្តកំពង់ចាម

1. *ខេត្តកំពង់ចាមជាប់ចំណាត់ថ្នាក់លេខ១ នៅក្នុងការសិក្សារបស់មូលនិធិអាស៊ី (Asia Foundation) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) កាលពីឆ្នាំ ២០០៦ ស្តីអំពីបរិយាកាសអាជីវកម្មនៅក្នុងខេត្តចំនួនដប់របស់កម្ពុជា ។*





## ចំណុចខ្លាំងរបស់ប្រទេស

ជាងមួយទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាបានចេញមុខជាអ្នកប្រកួតប្រជែងក្នុងតំបន់ដ៏រឹងមាំនិងសកម្ម ដោយមានភោគទ្រព្យយ៉ាងសម្បូរបែប ដែលមានសារៈសំខាន់បំផុតសំរាប់កំណើន និងការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយជោគជ័យ ។

**បើកទូលាយសំរាប់អាជីវកម្ម**

- ពន្ធលើប្រាក់ចំណេញដែលមានតម្លៃទាប – ពន្ធ ២០% លើប្រាក់ចំណេញ ( ការខាតបង់ ៥ ឆ្នាំទៅមុខ)
- ពុំមានការកំណត់លក្ខខណ្ឌកាន់កាប់បរទេសទេ។ ប្រទេសកម្ពុជាអនុញ្ញាតឱ្យមានសម្ព័ន្ធអាជីវកម្មរួមគ្នា ឬក្រុមហ៊ុនដែលកាន់កាប់ដោយបរទេសប្រតិបត្តិការ ១០០% ដោយមានសិទ្ធិពេញលេញ ដែលអាចនាំចូល និងនាំចេញផលិតផលបានស្ទើរគ្រប់ប្រភេទ។
- វិនិយោគិនទាំងអស់ទទួលបានការការពារប្រកបដោយសមភាព។
- ប្រទេសកម្ពុជាមានសេរីភាពសេដ្ឋកិច្ចជាងប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី[2]។
- ពុំមានការគ្រប់គ្រងតម្លៃផលិតផល ឬសេវាណាមួយទេ ។
- ពុំមានការគ្រប់គ្រងការប្តូររូបិយប័ណ្ណបរទេស ឬការកំណត់លក្ខខណ្ឌទៅលើការប្តូររូបិយប័ណ្ណនេះទេ ។
- ពុំមានការកំណត់លក្ខខណ្ឌស្តីពីការបង្វិលទុនទេ ។
- សមាជិកភាពអង្គការពាណិជ្ជកម្មពិភពលោក និង អាស៊ាន។
- ពុំមានការកំណត់លក្ខខណ្ឌពាណិជ្ជកម្មបរិមាណ និងមានការទំលាក់ថ្លៃរបាំងពន្ធគយទេ។ ប្រទេសកម្ពុជាអាចទទួលបានការលើកលែងពន្ធ និងការកំណត់កូតានៅលើទីផ្សារពិភពលោកធំៗដូចជា សហរដ្ឋអាមេរិក សហភាពអឺរ៉ុប ជប៉ុន និងបណ្តាប្រទេសសមាជិកអាស៊ានជាច្រើនទៀត ។
- អជ្ញាធរខេត្តមានសិទ្ធអនុម័តការវិនិយោគទុនក្រោម២លានដុល្លារ ដើម្បីធ្វើអោយការចាប់ផ្តើមអភិវឌ្ឍន៍អាជីវកម្មបានឆាប់រហ័ស ។

*"ប្រទេសកម្ពុជា បើកទូលាយយ៉ាងពេញលេញសំរាប់អាជីវកម្ម ហើយរាជរដ្ឋាភិបាលកម្ពុជានឹងព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីធានានូវបរិយាកាសគួរជាទីពេញចិត្ត និងជោគជ័យដល់គ្រប់សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។"*

– សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## កំលាំងពលកម្មដែលមានតម្លៃទាប

បើប្រៀបធៀបទៅនឹងដៃគូប្រកួតប្រជែងក្នុងតំបន់ជាច្រើន ប្រទេសកម្ពុជារីករាយនឹងទទួលយកអត្រាប្រាក់ឈ្នួលទាបសមរម្យក្នុងគោលបំណងទាក់ទាញឧស្សាហកម្មដែលប្រើកំលាំងពលកម្មច្រើន ។

ឆ្លងកាត់ជាច្រើនឆ្នាំចុងក្រោយនេះ កំលាំងពលកម្មនៅប្រទេសកម្ពុជា បានកើនឡើងជាង ៥០% ច្រើនជាងពីរដងនៃអត្រានៅក្នុងប្រទេសសមាជិកអាស៊ានផ្សេងទៀត[3]។ ហើយដោយសារមានប្រជាជនវ័យក្មេងចំនួនច្រើន ( ចំនួនពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ) ទើបធ្វើឱ្យកំណើននៃកំលាំងពលកម្មនេះនឹងបន្តកើនឡើង ។

## ប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរ[4]

| ប្រទេស | អត្រាប្រាក់ឈ្នួលក្នុងមួយម៉ោង (US$) |
|---|---|
| កម្ពុជា | 0.33 |
| ចិន | 0.88[a]/0.66[b] |
| ប៉ាគីស្ថាន | 0.41 |
| ឥណ្ឌា | 0.38 |
| ឥណ្ឌូនេស៊ី | 0.30 |
| បង់ក្លាដេស | 0.39 |

## ទីតាំងយុទ្ធសាស្រ្តក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅចំកណ្តាលតំបន់ ដែលមានសក្តានុពលបំផុតនៅលើពិភពលោក។ នៅចន្លោះប្រទេសថៃ និងប្រទេសវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែកមួយនៃច្រកសេដ្ឋកិច្ចខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ ដែលលាតសន្ធឹងចេញពីទីក្រុងហូជីមិញរហូតដល់ទីក្រុងបាងកក ។

ដោយសារទីតាំងយុទ្ធសាស្រ្តរបស់ខ្លួន ប្រទេសកម្ពុជាបានរីករាយនឹងទទួលយកការគាំទ្រដ៏សំខាន់ពីសំណាក់អន្តរជាតិ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងប្រទេស និងជាមួយប្រទេសជិតខាង។ ជាលទ្ធផល ពាណិជ្ជកម្មជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃកំពុងតែរីកចម្រើនឡើងយ៉ាងឆាប់រហ័ស។




*"អ្នកមានទីក្រុងធំជាងគេចំនួនពីរនៅក្នុងអាស៊ីតំបន់ដែលនៅអមប្រទេសអ្នក។ អ្នកមានប្រជាជន ១៥ លាននាក់នៅទីក្រុងបាងកក និង ៨ លាននាក់ នៅទីក្រុងហូជីមិញ ហើយកំណើនផ្សេងៗមានការកើនឡើងជាលំដាប់នៅភាគកណ្តាលនៃទីក្រុងទាំងពីរ ។"*

- Edward Hopkins, CB Richard Ellis Group Inc.

2. *The Heritage Foundation លិបិក្រមនៃសេរីភាពសេដ្ឋកិច្ចឆ្នាំ ២០០៨ ។ http://www.heritage.org/index/*

3. *ILO "និន្នាកាសង្គម និងពលកម្មនៅក្នុងអាស៊ាន ឆ្នាំ ២០០៧ - សមាហរណកម្ម បញ្ហាប្រឈម និងឱកាស " ឆ្នាំ ២០០៧ ។*

4. *ចំណាំ: a) តំបន់ឆ្នេរ b) តំបន់ដីគោក*





# តើហេតុអ្វីជ្រើសរើសយកខេត្តកំពង់ចាម?

## ១. បរិយាកាសអាជីវកម្មល្អបំផុតនៅក្នុងប្រទេសកម្ពុជា

ដោយមានទីតាំងស្ថិតនៅចំកណ្ដាលប្រទេសកម្ពុជា បរិយាកាសអាជីវកម្មនៅខេត្តកំពង់ចាម គឺជាបរិយាកាសល្អបំផុតរបស់កម្ពុជា។ ថ្មីៗនេះ ខេត្តកំពង់ចាមទទួលចំណាត់ថ្នាក់លេខ១ ក្នុងចំណោមខេត្តនានារបស់កម្ពុជា ដោយសារបរិយាកាសគាំទ្រដល់អាជីវកម្មរបស់ខេត្តនេះ។ នៅខេត្តកំពង់ចាម យើងធ្វើគ្រប់បែបយ៉ាងតាមដែលយើងអាចធ្វើបាន ដើម្បីផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព ដែលមានសក្តានុពលសំរាប់អាជីវកម្មរបស់អ្នក។

ចំណាត់ថ្នាក់របស់យើងទទួលបានតាមរយៈការសិក្សារួមគ្នារបស់មូលនិធិអាស៊ី និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ កាលពីឆ្នាំ២០០៦ ស្តីអំពីការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា (PBES)[5] ។ ការវាយតម្លៃនេះវាស់វែងទៅលើការគ្រប់គ្រងសេដ្ឋកិច្ច និងគោលនយោបាយច្បាប់ ដោយសារមានការពាក់ព័ន្ធទៅនឹងការគាំទ្រដល់បរិយាកាសអាជីវកម្មយ៉ាងសកម្ម និងផុសផុល ។

ជាមោទនភាពណាស់ ដែលការវាយតម្លៃរកឃើញថា កត្តាមួយចំនួនខាងក្រោមនេះពាក់ព័ន្ធនឹងបរិយាកាសអាជីវកម្មរបស់ខេត្តកំពង់ចាមយើងនេះ:

### ថ្លៃសុំសិទ្ធិចូលវិនិយោគទាបបំផុត

ខេត្តកំពង់ចាមបានបង្កើតប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មមួយ ដ៏មានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសដែលតំណាងដោយថ្លៃអាជ្ញាប័ណ្ណទាប លក្ខខណ្ឌមានកំណត់សំរាប់អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតពិសេស ហើយជាទូទៅមានរយៈពេលចុះបញ្ជីលឿនបំផុត ។

| សូចនាករអំពីថ្លៃសុំសិទ្ធិចូលវិនិយោគ | ថ្ងៃ* | ថ្លៃ $* |
|---|---|---|
| លិខិតបញ្ជាក់ការចុះបញ្ជីនៅក្នុងខេត្ត | 10 | 3.75 |
| អាជ្ញាប័ណ្ណប្រតិបត្តិការនៅក្នុងខេត្ត | 7 | 2.25 |
| លិខិតបញ្ជាក់ការបង់ពន្ធប៉ាតង់ | 15 | 5.50 |

* ជាមធ្យម

### ធានាដល់ច្បាប់កម្មសិទ្ធិខ្ពស់បំផុត

ខេត្តកំពង់ចាម ទទួលបានចំណាត់ថ្នាក់លេខមួយផ្នែកកម្មសិទ្ធិ។ យើងខំប្រឹងឱ្យអស់ពីសមត្ថភាព ដើម្បីធានាដល់សិទ្ធិជាផ្លូវការនៃអាជីវកម្ម ដើម្បីធ្វើប្រតិបត្តិការ និងធានាដល់សិទ្ធិកាន់កាប់ដីធ្លី ហើយយើងធ្វើកិច្ចការនេះបានល្អជាងខេត្តដទៃទៀត។

| សូចនាករស្តីពីច្បាប់កម្មសិទ្ធិ | ក្រុមហ៊ុន |
|---|---|
| ឯកសារកាន់កាប់ដីរបស់គ្រួសារ និងអាជីវកម្ម | 92% |
| ប្លង់រឹង | 36% |
| ការពិចារណាអំពីការដកហូតសិទ្ធិជារឿយៗ ឬតែងតែជាគ្រោះថ្នាក់ | 0% |
| ការពិចារណាអំពីការផ្លាស់ប្តូរសម្ភារៈនៅក្នុងកិច្ចសន្យាជួលមានកំរិតខ្ពស់ ឬខ្ពស់ខ្លាំង | 14% |
| ការជួលពីរដ្ឋ | 0% |

### គោលនយោបាយ និងច្បាប់ដ៏មានតម្លាភាព

បណ្តាក្រុមហ៊ុននៅខេត្តកំពង់ចាមមានឱកាសល្អបំផុត ក្នុងការទទួលបានឯកសារស្របច្បាប់ដែលចាំបាច់សំរាប់ដំណើរការអាជីវកម្មរបស់ខ្លួន។ ឯកសារទាំងនេះ អាចរកបានដោយស្មើភាពគ្នា ហើយគោលនយោបាយ និងច្បាប់ថ្មីមានការទំនាក់ទំនងទៅនឹងបណ្តាក្រុមហ៊ុន ហើយមានការអនុវត្តដែលអាចព្យាករណ៏បាន។

ពាក្យសុំ និងព័ត៌មានអំពីការចុះបញ្ជី និងអាជ្ញាប័ណ្ណសំរាប់អាជីវកម្មមានត្រៀមរួចជាស្រេចនៅការិយាល័យនៃមន្ទីរពាណិជ្ជកម្ម និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរបស់យើង។ មិនដូចជាខេត្តដទៃទៀតទេ អ្នកមិនចាំបាច់ធ្វើការទំនាក់ទំនងទៅមន្ត្រីខេត្តនេះ ដើម្បីទទួលបានព័ត៌មាននេះទេ។

### រយៈពេលអនុវត្តតាមច្បាប់តិចបំផុត

បណ្តាអាជីវកម្មដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ចាម ចំណាយពេលក្នុងការអនុវត្តតាមច្បាប់ និងរង់ចាំតិចជាងខេត្តដទៃទៀតនៅក្នុងប្រទេសកម្ពុជា។ បណ្តាក្រុមហ៊ុនរបស់យើងក៏មានការធ្វើអធិការកិច្ចពី ទីភ្នាក់ងារច្បាប់ក្នុងស្រុកតិចជាងខេត្តដទៃទៀតដែរ។

| សូចនាករ | |
|---|---|
| បណ្តាក្រុមហ៊ុនដែលចំណាយពេលច្រើនជាង ១៦ថ្ងៃ ក្នុងមួយឆ្នាំទៅលើនីតិវិធីការិយាល័យធិបតេយ្យ (%) | 14 |
| ការធ្វើអធិការកិច្ចសរុបប្រចាំឆ្នាំ (ចំនួនធ្វើអធិការកិច្ចជាមធ្យម) | 4 |
| រង់ចាំប្លង់ដី (ចំនួនថ្ងៃជាមធ្យម) | 30 |

### ការចូលរួមពីវិស័យឯកជនដ៏ខ្លាំងក្លាក្នុងគោលនយោបាយ

នៅចុងបញ្ចប់ យើងពិភាក្សាអំពីអាជីវកម្មរបស់យើងជាញឹកញាប់ និងហ្មត់ចត់ជាងខេត្តដទៃទៀត ដើម្បីធានាថាតម្រូវការ និងបញ្ហារបស់អ្នកត្រូវបានដោះស្រាយនៅក្នុងការអភិវឌ្ឍន៍គោលនយោបាយខេត្ត។

យើងមានមោទនភាពណាស់ដែលបានបង្កើតបរិយាកាសមួយ ដែលគាំទ្រដល់តម្រូវការនានា និងផ្តល់នូវប្រយោជន៏អាជីវកម្មរបស់យើង ហើយយើងទន្ទឹងរង់ចាំស្វាគមន៏ចំពោះអាជីវកម្មច្នៃប្រឌិតថ្មីៗ និងកំពុងនឹងដំណើរការបន្ថែមទៀតមកដល់ខេត្តរបស់យើង ។

## ២. ទីតាំង - មជ្ឈមណ្ឌលដឹកជញ្ជូននៅចំកណ្តាលប្រទេសកម្ពុជា

ខេត្តកំពង់ចាមមានទីតាំងនៅចំកណ្តាលប្រទេស ហើយមានព្រំដែនជាប់នឹងប្រទេសវៀតណាម។ ដោយសារខេត្តកំពង់ចាមស្ថិតនៅជិត និង មានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ដូច្នេះខេត្តនេះទទួលបានការដាក់លក់កសិផល-ផលិតផលមួយចំនួនទៀតរបស់ខេត្តនៅលើទីផ្សារដ៏ធំមួយ ដូចជាជ័រកៅស៊ូជាដើម ហើយកសិផលត្រូវបាននាំចេញពីខេត្ត ឬឆ្លងកាត់ខេត្តទៅប្រទេសវៀតណាមក្នុងបរិមាណដ៏ច្រើន។

5. *ការវាយតម្លៃបរិយាកាសអាជីវកម្មរបស់បណ្តាខេត្តនានា ក្នុងឆ្នាំ ២០០៦ របស់មូលនិធិអាស៊ី និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ នៅកម្ពុជាបានវាស់វែងអាជីវកម្មចំនួន ៥០០ នៅក្នុងខេត្តក្រុងចំនួនដប់: ភ្នំពេញ សៀមរាប កំពត បាត់ដំបង កំពង់ចាម កណ្តាល បន្ទាយមានជ័យ ស្វាយរៀង កំពង់ឆ្នាំង និងក្រុងព្រះសីហនុ ។*

# តើហេតុអ្វីជ្រើសរើសយកខេត្តកំពង់ចាម?





ខេត្តនេះមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនដ៏ប្រសើរ ហើយជាមជ្ឈមណ្ឌលដឹកជញ្ជូន និងពាណិជ្ជកម្មមួយ ដែលបម្រើដល់តំបន់មួយចំនួនធំនៅក្នុងប្រទេសកម្ពុជា ឆ្លងកាត់តាមទម្រង់ដឹកជញ្ជូនផ្សេងៗគ្នា ។

**កម្ពុជា_ខេត្តកំពង់ចាម រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុង បាងកក និងហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែនទេ ។

## បណ្តាញផ្លូវគោក

ខេត្តកំពង់ចាមមានផ្លូវជាតិទាំងអស់ចំនួន ១១ ខ្សែមានប្រវែង ៤៤០គ.ម (ជិត ១១% នៃផ្លូវជាតិនៃប្រទេសកម្ពុជាសរុប) ។ ជាលទ្ធផល ខេត្តកំពង់ចាមមានផ្លូវជាតិ ប្រកបដោយគុណភាពជាច្រើនគីឡូម៉ែត្រដែលមានកំរិតគុណភាពល្អលើសផ្លូវជាតិដទៃទៀតចំនួន ២ ដងក្នុងទំហំដីមួយគីឡូម៉ែត្រការ៉េ ។

ពីភ្នំពេញមកទីរួមខេត្តកំពង់ចាមបើកបររយៈពេលតែ ២ម៉ោងប៉ុណ្ណោះ ហើយពីទីក្រុងហូជីមិញមកទីរួមខេត្តកំពង់ចាម បើកបរតែរយៈពេល ៤ម៉ោងកន្លះ ។ ពាណិជ្ជកម្មជាមួយប្រទេសវៀតណាម ប្រើប្រាស់ច្រកចេញចូល ចំនួន ៦កន្លែង (កន្លែងត្រួតពិនិត្យព្រំដែនអន្តរជាតិ ១កន្លែង កន្លែងត្រួតពិនិត្យទ្វេរភាគី ១កន្លែង និងកន្លែងត្រួតពិនិត្យក្នុងតំបន់ ៤កន្លែង) ។

## បណ្តាញផ្លូវដែក

រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើការកសាងផ្លូវដែកមួយខ្សែចេញពីខេត្តកណ្តាលឆ្លងកាត់តាមខេត្តកំពង់ចាមរហូតដល់ខេត្ត ឡុក និញ (Loc Ninh) ប្រទេសវៀតណាម ។ ផ្លូវដែកដែលមានប្រវែង ២៥៥ គ.ម មួយខ្សែនេះ នឹងជួយសម្រួលដល់វិស័យដឹកជញ្ជូន និងពាណិជ្ជកម្មឱ្យកាន់តែប្រសើរថែមទៀតរវាងខេត្តកំពង់ចាម និងប្រទេសវៀតណាម ។

## ទន្លេ

ខេត្តកំពង់ចាមមានទីតាំងស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ ដែលហូរកាត់តាមប្រទេសឡាវភាគឦសាន ប្រទេសកម្ពុជា និងហូរចាក់ទៅប្រទេសវៀតណាម ដែលជួយសម្រួលដល់ការធ្វើដំណើរ និងការដឹកជញ្ជូនផលិតផលយ៉ាងច្រើនសន្ធឹកសន្ធាប់ ទន្លេនេះជាសញ្ញាណដ៏សំខាន់របស់ខេត្ត និងជាបណ្តាញដឹកជញ្ជូនផងដែរ ។

## ៣. តំបន់សេដ្ឋកិច្ចពិសេសឈានមុខគេ ដើម្បីជំរុញលើកទឹកចិត្តពាណិជ្ជកម្ម ដែលអាចរកប្រាក់ចំណេញបាន

ខេត្តកំពង់ចាមជាទីតាំងតំបន់សេដ្ឋកិច្ចពិសេសឈ្មោះ Thary Kg Cham SEZ ។ ដោយមានទីតាំងស្ថិតនៅក្នុងស្រុកមេមត់តំបន់ដែលមានផ្ទៃដី ១៤២ ហិចតានេះមានចំងាយ១៦០គ.មគត់ចាប់ពីទីក្រុងហូជីមិញមក ហើយផ្តល់ផលប្រយោជន៍បន្ថែមទៀតដូចខាងក្រោម:

- ការផ្តល់អាជ្ញាប័ណ្ណដែលមានប្រសិទ្ធភាព
- អំឡុងពេលក្រុមហ៊ុនមិនចាំបាច់បង់ពន្ធ ចន្លោះពេលពី ៣ ទៅ ៦ឆ្នាំ
- ការលើកលែងពន្ធនាំចូលពេញលេញ
- ពុំមានពន្ធនាំចេញ
- ហេដ្ឋារចនាសម្ព័ន្ធថ្នាក់ពិភពលោក
- ទឹក និងអគ្គិសនីថោកជាង ១០%

## ៤. កំលាំងពលកម្ម – ច្រើន វ័យក្មេង មានការអប់រំ តម្លៃឈ្នួលពលកម្មទាប

ក្រៅពីរាជធានី ខេត្តកំពង់ចាមគឺជាខេត្តដែលមានចំនួនប្រជាប្រជនច្រើនជាងគេបំផុតគឺ ១.៧ លាននាក់ ។ ចំនួនប្រជាជនជិត ៦០% មានអាយុក្រោម ២៥ឆ្នាំ-កំលាំងពលកម្មរបស់យើងមានវ័យក្មេង ពេញចិត្តនឹងការងារ និងមានការអប់រំ ។

### ប្រជាសាស្ត្រអនុគ្រោះ[6]




អត្រាចុះឈ្មោះចូលរៀនអនុវិទ្យាល័យ និងអក្ខរកម្មរបស់ខេត្ត ត្រូវបានរៀបចំទីតាំងបានយ៉ាងល្អទូទាំងខេត្ត ដោយមានសិស្ស ៤២៥ ០០០នាក់ ចូលរៀននៅសាលាបឋមចំនួន ៧៦៣ អនុវិទ្យាល័យចំនួន ៨៦ និង វិទ្យាល័យចំនួន ៤០ ។

ការចំណាយទៅលើការអប់រំនៅបឋមសិក្សា ដែលជាផ្នែកមួយនៃផលិតផលក្នុងស្រុកសរុប (GDP) បានកើនឡើងគួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបច្ចុប្បន្ននេះមានកំរិតប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសថៃដែរ ។ ខេត្តកំពង់ចាមមិនឈប់ត្រឹមនេះទេ អាជ្ញាធរមានផែនការបន្តបង្កើនការចំណាយទៅលើការអប់រំបន្តទៀត ។

6. *តារាងនេះគឺសំរាប់រាល់ប្រជាជនកម្ពុជាទាំងអស់ ។ ប្រភព: វិទ្យាស្ថានជាតិស្ថិតិ ជម្រឿនប្រជាជននៅក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០៤ ។*






ដោយមានប្រព័ន្ធអប់រំប្រកបដោយប្រសិទ្ធភាពនោះ វាមិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលកំលាំងពលកម្មខេត្តកំពង់ចាមបានអភិវឌ្ឍន៍ ក្នុងនោះមានកំលាំង ៣១% ធ្វើការនៅក្នុងវិស័យសាធារណៈ និងឧស្សាហកម្ម។

យើងមានមោទនភាពណាស់ ដែលមានធនធានមនុស្សឈានមុខគេក្នុងការគាំទ្រអាជីវកម្មរបស់យើង ហើយជឿជាក់ថាការងារនេះជាឧត្តមភាពក្នុងការប្រកួតប្រជែងដ៏ខ្លាំងក្លាបំផុតមួយរបស់យើង - អនុញ្ញាតឱ្យប្រជាពលរដ្ឋយើង ជួយធ្វើឱ្យសហគ្រាសរបស់អ្នកឱ្យកាន់តែមានភាពប្រសើរថែមទៀត។

## ៥. វិស័យសេវាកម្មហិរញ្ញវត្ថុដ៏ខ្លាំងក្លា

វិស័យហិរញ្ញវត្ថុសាធារណៈខេត្តអភិវឌ្ឍបានល្អណាស់។ ធនាគារចំនួន ៥ នៅក្នុងខេត្តមានសាខាចំនួន ២៣ - មានសាខាធនាគារច្រើនជាងខេត្តដទៃទៀតក្រៅពីភ្នំពេញ។

យើងក៏មានកំចីមីក្រូហិរញ្ញវត្ថុធំជាងគេបំផុតក្រៅពីដើមទុនផងដែរ។ អាជីវកម្មរបស់យើងទទួលបានដើមទុន ដែលចាំបាច់ដើម្បីធ្វើការវិនិយោគដែលផ្តល់ផលខ្ពស់។

## ៦. អចលនទ្រព្យមានតម្លៃខ្ពស់លើសលប់

យើងគាំទ្រ និងសហការយ៉ាងសកម្មជាមួយនឹងក្រុមហ៊ុននានា ដើម្បីធានាបាននូវសម្បទានដីធ្លីដែលមាននិរន្តរភាព និងសមស្រប។ រហូតមកដល់ពេលនេះ អាជីវកម្មនៅក្នុងខេត្តរបស់យើងបានរក្សាសុវត្ថិភាពដីជាង ១៤ ៦០០ ហិកតា សំរាប់ផលិតកម្មដំណាំសំខាន់ៗ និងដំណាំដែលផ្តល់ផលពីរដងក្នុងមួយឆ្នាំ។

### សម្បទានដីដែលបានផ្តល់

| ក្រុមហ៊ុន | ប្រើប្រាស់ | ទំហំ (ហិចតា) |
|---|---|---|
| Men Sarun Co. | ដំណាំកៅស៊ូ និង ដំណាំផ្សេងៗ | 4,400 |
| Merng Liheng Co. | ទំនេរ | 3,000 |
| Vann Ma Co. | កសិកម្ម និង កសិឧស្សាហកម្ម | 1,200 |
| Bigi Mexico Sothy Aphivath Co Ltd | ដំណាំកៅស៊ូ និងស្វាយចន្ទី | 980 |
| Heng Chay Ngim Aphivath | ដំណាំកៅស៊ូ និងដំណាំផ្សេង | 600 |
| Thary Aphivath | ដំណាំកៅស៊ូ | 832 |
| Heng Sok Nguon Investment | ដំណាំកៅស៊ូ | 832 |
| Agrostar | ស្វាយចន្ទី និងការចិញ្ចឹមសត្វ | 1,993 |
| Khmer Le Tech | ដំណាំកៅស៊ូ និងការកែច្នៃជ័រកៅស៊ូ | 60 |
| Kobe Bussan Cambodia | បន្លែសម្រាប់នាំចេញ | 1,800 |

## ៧. ការផ្គត់ផ្គង់អគ្គិសនី

ខេត្តកំពង់ចាមទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីពីប្រភពមួយចំនួន។ អគ្គិសនីកម្ពុជាដែលជារបស់រដ្ឋសហការរួមគ្នាជាមួយ GTS ផ្គត់ផ្គង់ ថាមពលអគ្គិសនីចេញពីស្ថានីយ៍ចំនួនបីនៅក្នុងទីរួមខេត្តកំពង់ចាម ស្រុកមេមត់ និងស្រុកពញាក្រែក។ ក្រៅពីនេះ មានស្ថានីយ៍អគ្គិសនីឯកជនចំនួន ៣៦ កន្លែងប្រតិបត្តិការនៅក្នុងខេត្ត។ ប្រភពថាមពលអគ្គិសនីសំខាន់ៗចំនួនមួយភាគបី ត្រូវបាននាំចូលពីវៀតណាម - ទៅស្រុកមេមត់ ស្រុកពញាក្រែក ។

ការផ្គត់ផ្គង់អគ្គិសនីទូទាំងខេត្ត ត្រូវបានរំពឹងថាមានភាពប្រសើរ ដោយមានការនាំចូលពីប្រទេសវៀតណាម ដែលនឹងមានការកើនឡើងនៅរយៈពេលមួយឆ្នាំទៅពីរឆ្នាំទៀត។

អគ្គិសនីនៅក្នុងទីរួមខេត្តកំពង់ចាម មានតម្លៃ ៩៥០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង (ប្រហែល ០.២៣ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង)។ អគ្គិសនីដែលនាំចូលពីប្រទេសវៀតណាមមានតម្លៃ ៦៥០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ។

# ឧស្សាហកម្មសំខាន់ៗរបស់ខេត្ត

ជោគជ័យរបស់យើងក្នុងការគាំទ្រវិស័យពាណិជ្ជកម្មដែលមានសកម្មភាពខ្លាំងក្លានេះ បានធ្វើឱ្យខេត្តកំពង់ចាមជាគោលដៅឈានមុខគេសំរាប់សហគ្រាសនានានៅក្នុងប្រទេស។ បច្ចុប្បន្ននេះយើងមានមោទនភាពដោយមានសហគ្រាសឯកជនជាង ៣០០០ កន្លែង ប្រតិបត្តិការនៅក្នុងខេត្តកំពង់ចាមដែលរួមមាន:

| សកម្មភាព | ចំនួនសហគ្រាស | ចំនួននិយោជិក |
|---|---|---|
| ការកែច្នៃជ័រកៅស៊ូ | 27 | មិនទាន់មាន |
| តម្បាញ | 2 | 2,000 |
| ការកែច្នៃគ្រាប់ស្វាយចន្ទី | 2 | 650 |
| ការកែច្នៃប្រេង | 1 | 50 |
| ម្សៅដំឡូង | 2 | 125-150 |
| កែច្នៃបន្លែ | 2 | 100-150 |
| ផលិតកម្មកាត់ដេរ | 2 | 1,900 |
| ផលិតកម្មភេសជ្ជៈ | 1 | 300 |
| អគ្គិសនីបានមកពីជីវម៉ាស | 1 | មិនទាន់មាន |
| ចំណីសត្វ | 1 | 35-65 |

ផលិតផលដែលបានមកពីអាជីវកម្មទាំងនេះជាច្រើន ត្រូវបាននាំចេញទៅប្រទេសវៀតណាម។

ខេត្តរបស់យើងគឺជាតំបន់ដែលមានរោងចក្រម្សៅដំឡូងមីចំនួនពីរ (Seav Fong Development Agriculture Co. និង Sun Ath Aphivath) ដែលរោងចក្រនីមួយៗផ្តល់លទ្ធភាពផលិត បានប្រហែល ២,២០០ តោន ក្នុងមួយឆ្នាំ។

ខេត្តរបស់យើងក៏ជាតំបន់សំរាប់ក្រុមហ៊ុនអន្តរជាតិឈានមុខគេជាច្រើន ទទួលស្គាល់ពីផលប្រយោជន៍ប្រតិបត្តិការនៅក្នុងខេត្តដែរ។ ក្រុមហ៊ុនថ្នាំជក់អាមេរិក-អង់គ្លេស ធ្វើការ





យ៉ាងសកម្មនៅក្នុងខេត្តកំពង់ចាមជាមួយកសិករក្នុងការផលិតស្លឹកថ្នាំជក់ ដែលក្នុងនោះមានកសិករប្រមាណ ៨០០ នាក់។

វិនិយោគិនជប៉ុន បច្ចុប្បន្ននេះកំពុងតែបង្កើតរោងចក្រកែច្នៃបន្លែនៅក្នុងខេត្តកំពង់ចាម ដែលបង្កើនតម្លៃបន្ថែមទៀតទៅលើផលិតផលបន្លែដ៏ធំជាងគេរបស់ប្រទេសកម្ពុជា។

រោងចក្រផលិតរបស់យើងកំពុងតែអភិវឌ្ឍន៍។ រោងចក្រកាត់ដេរ ចំនួនពីរប្រតិបត្តិនៅក្នុងខេត្តនេះ រោងចក្រមួយមានប្រតិបត្តិការនៅក្នុងទីរួមខេត្តកំពង់ចាម និងរោងចក្រមួយទៀតមានប្រតិបត្តិការអាជីកម្មនៅស្រុកមេមត់ទល់ព្រំដែនវៀតណាម ។

ខេត្តកំពង់ចាមក៏ជាខេត្តដែលផ្គត់ផ្គង់ចំណីសត្វ គ្រឿងចក្រកសិកម្ម និង ជីរកសិកម្ម រោងម៉ាស៊ីនកិនស្រូវ ឡឥដ្ឋ ផលិតកម្មគ្រឿងសង្ហារឹម និងប្រតិបត្តិការឧស្សាហកម្មតូចៗផ្សេងទៀតផងដែរ។

អាជីវកម្មតូចៗជាច្រើនប្រតិបត្តិការក្នុងខេត្ត ដែលបានចុះបញ្ជីធ្វើអាជីវកម្មជិត ១០០០ នៅសាលាខេត្តរបស់យើង។ បន្ថែមពីលើនេះទៀត មានសហគ្រាសធុនតូចរាប់ពាន់រួមមាន

- ម៉ាស៊ីនកិនស្រូវ
- ម៉ាស៊ីនភ្លើង
- ផលិតកម្មគ្រឿងសង្ហារឹម
- សិប្បកម្ម
- សេវាជួសជុលគ្រឿងចក្រ
- លក់ដុំ និងលក់រាយ
- សេវាសណ្ឋាគារ និងបដិសណ្ឋារកិច្ច និង
- សេវាសុខភាព ។

## ឱកាសអាជីវកម្ម

ខេត្តរបស់យើងផ្តល់ឱកាសជាច្រើនសំរាប់អាជីវកម្មថ្មីៗ ដែលបង្ហាញយ៉ាងច្បាស់ដោយក្រុមហ៊ុនទាំងឡាយជាច្រើនប្រភេទ ដែលបានប្រតិបត្តិការនៅទីនេះស្រាប់។ យើងមើលឃើញឱកាសសំខាន់ៗសំរាប់អាជីវកម្ម ដើម្បីទាញយកផលប្រយោជន៍ពីកំលាំងប្រកួតប្រជែងតាមរយៈការវិនិយោគទុនបន្ថែមទៀតនៅក្នុងវិស័យ:

- **កសិកម្ម** យើងមានដីធំទូលាយ (ដីមានជីរជាតិ ៨០% កំលាំងការងារ កំលាំងអូសទាញ និងប្រភពទឹកក្រោមដី។ ឧទាហរណ៍: ដីមួយហិកតានៅក្នុងខេត្តកំពង់ចាមដំឡូងមីអាចផ្តល់ទិន្នផលរហូតដល់ ៤០ តោនដែលតិតជាប្រាក់ប្រហែល ២,៥០០ ដុល្លារ។ រោងចក្រជីរអេតាណុល ដែលបានបើកនៅពេលថ្មីៗនេះ នៅក្នុងខេត្តកណ្តាល នឹងប្រើដំឡូងមីមកពីខេត្តកំពង់ចាម និងខេត្តដទៃទៀត ដែលនឹងបង្កើនតម្រូវការសំរាប់ដំណាំនេះ។

- **កសិពាណិជ្ជកម្ម** ជាពិសេសការកែច្នៃចំណីអាហារ។ យើងមាន ឱកាសសំខាន់ក្នុងការបន្ថែមតម្លៃទៅលើទិន្នផលកសិកម្មយ៉ាងច្រើនផ្សេងៗគ្នា។ ដំឡូងមីស្រស់ និងរោងចក្រម្សៅដំឡូងមីទទួលបានជោគជ័យ នៅក្នុងខេត្តកំពង់ចាម ហើយមានវិសាលភាពសំរាប់ការបង្កើនសមត្ថភាពកាន់តែធំថែមទៀត។

- **វារីវប្បកម្ម** យើងមានប្រភពទឹកធម្មជាតិ និងជំនាញ និងចំណេះដឹង នៅក្នុងឧស្សាហកម្មនេះស្រាប់។ កសិករធ្វើស្រែជាច្រើននៅក្នុងខេត្តកំពង់ចាមចូលចិត្តចិញ្ចឹមត្រីនៅក្នុងស្រែប្រសិនបើពួកគាត់អាចទទួលបានកូនត្រីគ្រប់គ្រាន់។ ក្រុមហ៊ុន Oceans King Company មានផែនការបង្កើតរោងចក្រកែច្នៃសាច់ត្រីនៅក្នុងទីក្រុងភ្នំពេញ ដោយតម្រូវការត្រីក្នុងស្រុកកើនឡើង ។

- **ឧស្សាហកម្មធុនស្រាល** រួមមានដូចជាវិស័យកាត់ដេរជាដើម។ កំលាំងពលកម្មជាច្រើន ដែលយកតម្លៃឈ្នួលពលកម្មទាប ហេដ្ឋារចនាសម្ព័ន្ធ និងបរិយាកាសអាជីវកម្មអំណោយផល។

## ការអភិវឌ្ឍន៍ដែលកំពុងដំណើរការ

ទោះបីជាយើង មានមោទនភាពចំពោះស្នាដៃនានារបស់យើងក៏ដោយ ក៏យើងនៅតែពង្រឹងនិងខិតខំទាក់ទាញផ្នែកវិនិយោគឱ្យកាន់តែមានភាពប្រសើរថែមទៀតដែរ។ យើងនៅតែសកម្មក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មរបស់យើង និងទាក់ទាញសហគ្រាសអាជីវកម្មឈានមុខគេឱ្យចូលមកខេត្តរបស់យើង។ ការអភិវឌ្ឍន៍សំខាន់ៗមួយចំនួននៅក្រោមវិធីសាស្រ្តរួមមានដូចតទៅ:

- **យុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មវិនិច្ឆ័យ** របស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្រោមកម្មវិធីនេះ ផលិតផលនៅក្នុងខេត្តកំពង់ចាម ជាច្រើនទទួលបានការគាំទ្របន្ថែមទៀត។ ផលិតផលដែលកំណត់អត្តសញ្ញាណដោយយុទ្ធសាស្រ្តនេះ រួមមានទាំងឧស្សាហកម្មកាត់ដេរ ស្បែកជើង និងស្រោមជើង ឧស្សាហកម្មធុនស្រាល កៅស៊ូ នេសាទ ដំឡូងមី ស្រូវ សូត្រ និងការដឹកជញ្ជូន។ ជំនួយរួមមានការសម្របសម្រួលផ្នែកពាណិជ្ជកម្ម និងការផ្សព្វផ្សាយពាណិជ្ជកម្ម កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រងនិងជំនាញក្នុងតំបន់។

- ដៃគូអភិវឌ្ឍន៍មួយចំនួនកំពុងជួយជ្រោមជ្រែងក្នុងការអភិវឌ្ឍន៍វិស័យឯកជននៅក្នុងខេត្តកំពង់ចាមក្នុងឧស្សាហកម្មសំខាន់ៗ

| គំរោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
|---|---|---|
| ការធ្វើឱ្យការយល់ដឹង និងការគ្រប់គ្រងជម្ងឺស្រូវកាន់តែមានភាពប្រសើរឡើង | ACIAR | ដំណាំស្រូវ |
| គម្រោងពង្រីកកសិកម្មអូស្រ្តាលី-កម្ពុជា ជំហានទី II | ACIAR | ដំណាំក្រៅពីដំណាំស្រូវដែលដាំលើដីទួល |
| គម្រោងពង្រីកកសិកម្មកម្ពុជា-អូស្រ្តាលី ដំណាក់កាលទី II (CAAEP II) | AusAID | កសិកម្ម |
| គម្រោងសេវាព័ត៌មានទីផ្សារកសិកម្ម (AMIS) | CIDA | ផ្លែឈើ និងបន្លែ |
| SPFS គាំទ្រដល់គ្រប់គ្រងធនធានធម្មជាតិ និងជីវចម្រុះ តាមរយ: សហគ្រាសក្រុមតូចៗ | FAO/ OPEC | ការចិញ្ចឹមសត្វតូចៗ ឃ្មុំ ផ្សិត ការកែច្នៃចំណីអាហារ ផលិតផលធម្មជាតិ ដែលមាននិរន្តរភាព |
| ការលើកកំពស់វិស័យឯកជន | GTZ | ដំឡូងមី ស្រូវសរីរាង្គ សូត្រ ពត៌មានវិទ្យា |
| គំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម | USAID | បសុសត្វ វារីវប្បកម្ម ការកែច្នៃកសិកម្ម |






## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័តិមានបន្ថែមស្តីអំពីឱកាសវិនិយោគ និងការអភិវឌ្ឍន៏នៅក្នុងខេត្តកំពង់ចាម

សូមទាក់ទង

លោក **យិន ប៊ុនទិត**

អនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការវិនិយោគខេត្ត

ទូរស័ព្ទ: (855) 42 941 106

**www.cambodiainvestment.gov.kh**

**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា - គណកម្មការវិនិយោគកម្ពុជា

Tel: (855) 23 981 154

www.cambodianinverstment.gov.kh

វិទ្យាស្ថានជាតិស្ថិតិ: www.nis.gov.kh

### ក្រសួងនានា

ក្រសួងពាណិជ្ជកម្ម:
www.moc.gov.kh

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:
www.mef.gov.kh

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល:
www.mine.gov.kh

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ::
www.mlv.gov.kh

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់:
www.mlmupc.gov.kh

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៏:
www.mptc.gov.kh

ក្រសួងសាធារណការណ៍ និងដឹកជញ្ជូន:
www.mpwt.gov.kh

ក្រសួងទេសចរណ៏:
www.mot.gov.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:
www.maff.gov.kh

### ផ្សេងៗ

សមាគមឧស្សាហកម្មកាត់ដេរនៅកម្ពុជា
www.gmac-cambodia.org

វេទិកាវិស័យឯកជន-រដ្ឋាភិបាល
www.cambodia-gpsf.org

សភាពាណិជ្ជកម្មភ្នំពេញ:
www.ppcc.org.kh

សមាគមឧស្សាហកម្មធុនតូច និងមធ្យមភ្នំពេញ:
www.smecambodia.org

## ស្ថិតិ

| ស្ថានភាពទូទៅខេត្តកំពង់ចាម | |
|---|---|
| ចំនួនប្រជាជន: | 1,802,546 |
| អាយុពី 15-64: | 57% |
| សមាមាត្រការងារក្នុងវិស័យកសិកម្ម: | 67% |
| លំដាប់ថ្នាក់ភាពក្រីក្ររបស់ខេត្ត: | 12/24 |
| ផ្ទៃដី: | 9,799 $km^2$ |
| ដង់ស៊ីតេប្រជាជន:<br>( % ចំនួនប្រជាជនជាមធ្យម) | 247% |
| ចំនួនស្រុក: | 16 |
| ចំនួនឃុំ: | 173 |

| ស្ថានភាពដីក្នុងខេត្តកំពង់ចាម |
|---|
| ប្រភេទ: ដីខុសៗគ្នា ដីល្បាប់ពណ៌ត្នោតបានពីទន្លេមេគង្គ ដីប្រផេះ ល្បាប់ និងដីជាំទឹកពណ៌ប្រផេះ និងដីក្រហមបាសាល |
| កម្រិតជីវជាតិ: ខ្ពស់ |

| អត្រាពន្ធនៅកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាប្រាក់លើកទឹកចិត្ត | 0% ឬ 9% |
| | | |
| ពន្ធអតិបរមា | | 1% ប្រាក់ចំណូល |
| ពន្ធកាត់ទុក | | 15% |
| ចំណូលបានមកពីការជួលអចលនទ្រព្យ | | 10% |
| ការទូទាត់ចំពោះមនុស្សចំណូលស្រុក | | 14% |
| | | |
| ពន្ធលើប្រាក់ខែ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| មនុស្សចំណូលស្រុក | អត្រាថេរ | 20% |
| ពន្ធផលប្រយោជន៍បន្ទាប់បន្សំ | | 20% |
| តម្លៃបន្ថែមលើពន្ធ | | 10% |
| | នាំចេញ | 0% |
| ពន្ធផ្ទេរអចលនទ្រព្យ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា | 2005 | 2006 | 2007 | 2008f | 2009f |
|---|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 7.5 | 7.0 |
| កំណើននាំចេញ (%) | 12.6 | 19.2 | 8.1 | 5.6 | 8.5 |
| នាំចេញ (% GDP) | 64.2 | 68.0 | 66.7 | 65.7 | 66.1 |
| FDI ($m) | 375 | 475 | 598 | 660 | 759 |
| FDI (% GDP) | 6.0 | 6.5 | 6.9 | 6.7 | 6.8 |

## ចំណាយអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| ភ្នំពេញ | $350-$2,000 |
| ដីពាណិជ្ជកម្ម | $30-$100 |
| តំបន់ផ្សេង | $4-$30 |
| ជនបទ | $0.50-$5 |
| **ដីសំរាប់ការិយាល័យ** | **តម្លៃជួលក្នុងមួយខែ** |
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ប្រាក់ជួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |
| ប្រាក់ជួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េក្នុងមួយខែ |

| តម្លៃពលកម្ម | ប្រាក់ខែ $ ក្នុងមួយខែ |
|---|---|
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | 1,000-1,500 |
| អ្នកគ្រប់គ្រងកណ្តាល | 500-1,000 |
| អ្នកគ្រប់គ្រងកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ជំនួយការ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាមទ្វារ | 50-80 |
| កម្មករ | 50-80 |
| ប្រាក់ឈ្នួលអប្បបរមារបស់កម្មករកាត់ដេរ | 60 |

| តម្លៃអគ្គិសនីនៅភ្នំពេញ (excl. SEZs) | | |
|---|---|---|
| ឧស្សាហកម្ម | គីឡូវ៉ាត់ម៉ោង/ខែ | តម្លៃ (រៀល/គីឡូវ៉ាត់) |
| | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | កំលាំងវ៉ុលជាមធ្យម | 480 |
| ការផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្ម | | $0.32/គ.ក្រ |

# ខេត្តកំពង់ចាម

# សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com